# សេចក្តីថ្លែងការណ៍ស្តីអំពី
# មូលនិធិរូបីយវត្ថុអន្តរជាតិ (IMF) បញ្ចប់បេសកម្មនៅកម្ពុជា

ភ្នំពេញ ថ្ងៃទី៦ ខែមិនា ឆ្នាំ២០០៩

គណៈប្រតិភូមួយក្រុមរបស់មូលនិធិរូបីយវត្ថុអន្តរជាតិបានធ្វើទស្សនៈកិច្ចមួយនៅប្រទេសកម្ពុជាកាលពីថ្ងៃទី២៥ ខែកុម្ភៈដល់ថ្ងៃទី៤ ខែមិនា ឆ្នាំ២០០៩ ដើម្បីពិនិត្យលើការ ការវិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងពេលថ្មីៗ។ គណៈប្រតិភូបានជួបពិភាក្សាជាមួយរដ្ឋមន្ត្រី មន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា និងតំណាងមកពីសមាគមន៍ពាណិជ្ជកម្ម និងដៃគូរអភិវឌ្ឍន៍នានា។

ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក និងវិបត្តិហិរញ្ញវត្ថុកំពុងតែប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាកាន់តែខ្លាំងឡើង ។ ទិន្នន័យនៃចំណូលអវិជ្ជមានដែលប្រមូលបានពីគ្រប់តំបន់នៃពិភពលោកព្រមទាំងការធ្លាក់ចុះជំនឿនៃអ្នកវិនិយោគ និងអ្នកប្រើប្រាស់ និងភាពចលាចលនៃទីផ្សារហិរញ្ញវត្ថុសកលលោក ចង្អុលបង្ហាញអោយឃើញថាបរិដ្ឋាននៃសេដ្ឋកិច្ចមានភាពប្រឈមយ៉ាងខ្លាំងខ្លាបំផុត ក្នុងឆ្នាំ២០០៩ និង២០១០ ។ ដូច្នេះនិទស្សន៍អំពីសេដ្ឋកិច្ចនៃប្រទេសកម្ពុជាសំរាប់ឆ្នាំនេះ និងឆ្នាំក្រោយសង្ឃឹមថានឹងមានភាពអនុគ្រោះតិចជាង ប្រៀបធៀបនឹងអ្វីដែលបានប្រមើលមើលនៅក្នុងកិច្ចពិគ្រោះយោបល់មាត្រាទី៤ (Article IV Consultation Discussion) ដែលបានផ្សព្វផ្សាយកាលពីដំណាច់ឆ្នាំ២០០៨ កន្លងទៅឡើយ។

ការនាំចេញនូវផលិតផលសំលៀកបំពាក់កំពុងរងនូវសំពាធដោយសារការធ្លាក់ចុះនៃតំរូវការលក់រាយនៅទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ។ ចំនួនភ្ញៀវទេសចរណ៍ថយចុះដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ចក្នុងប្រទេសនានាដែលជាប្រភពទេសចរចំបងៗបង្ខំកាត់បន្ថយការចំណាយ ។ ម៉្យាងវិញទៀតអតិផរណាខ្ពស់ក្នុងឆ្នាំកន្លងទៅ គួបផ្សំនឹងការកើនថ្លៃនៃប្រាក់ដុល្លារអាមេរិក និងប្រាក់រៀលបានធ្វើអោយប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់កម្ពុជា ។ សកម្មភាពសំណង់ និងការវិនិយោគទុនបរទេសមានភាពយឺតយ៉ាវ ដោយសារការធ្លាក់ចុះនៃចំនួនវិនិយោគិនក្រៅស្រុក និងដោយសារលក្ខខណ្ឌហិរញ្ញប្បទានមានភាពចង្អៀត ។ កសិកម្មមានដំណើរការល្អជាងការគិតរំពឹងនៅឆ្នាំកន្លងទៅ ក៏ប៉ុន្តែការធ្លាក់ចុះនៃថ្លៃទំនិញកសិផលធ្វើអោយការទាញយកផលប្រយោជន៍ពីវិស័យកសិកម្មក្នុងឆ្នាំនេះមានកំរិត ។

ផ្អែកលើបរិការណ៍នេះ ផលិតផលសរុបពិតក្នុងឆ្នាំ២០០៩នេះធ្លាក់ចុះ០,៥ % ។ ដោយសារតែស្ថានការណ៍សកលលោកប្រែប្រួលកាន់តែលឿនឡើងនាំអោយភាពមិនប្រាកដប្រជាជុំវិញការធ្វើព្យាករណ៍នេះមានទំហំធំជាងធម្មតា ហើយហានិភ័យនៅតែមានចំពោះភាពថយចុះ។ ការប្រមើលមើលសំរាប់ឆ្នាំ២០១០គឺនៅមានភាពមិនច្បាស់លាស់យ៉ាងខ្លាំងគឺវាជាប់ទាក់ទិនយ៉ាងសំខាន់ទៅលើទិដ្ឋភាពកំណើនសេដ្ឋកិច្ចពិភពលោក និង ក្នុងតំបន់។ កំណត់សំគាល់ជាវិជ្ជមានមួយគឺ អតិផរណាថយចុះស្របតាមថ្លៃប្រេង និងថ្លៃម្ហូបអាហារដែលទាបជាងមុន និងការថយចុះនៃសំពាធនៃសេចក្តីត្រូវការក្នុងស្រុក។ កត្តាទាំងនេះគួរតែបន្តរុញច្រានអតិផរណាអោយចុះមកត្រឹមលេខមួយខ្ទង់ក្នុងឆ្នាំនេះ។

កិច្ចពិភាក្សាអំពីគោលនយោបាយបានផ្តោតទៅលើ វិធានការសមស្របដើម្បីឆ្លើយតបទៅនឹងការរំពឹងថាមានការថ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ច ។ គណៈប្រតិភូ និងរាជរដ្ឋាភិបាលបានឯកភាពគ្នាថាត្រូវការ **សារពើពន្ធលើកស្ទួយ** (fiscal stimulus) ដែលធំជាងទំហំធំដែលបានគិតទុកមុនក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០០៩ ។ នៅក្នុងបរិការណ៍នេះឱនភាពថវិកាសរុបគួរតែអនុញ្ញាតអោយកើនឡើងដល់៩,៧៥%នៃផលិតផលក្នុងស្រុកសរុប ដោយមិនធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍នៃសារពើពន្ធដែលសំរេចបានក្នុងពេលថ្មីៗនេះទេ ឬក៏មិនធ្វើអោយកើនឡើងនូវភាពងាយរងគ្រោះដោយសារកត្តាក្រៅស្រុក ។ គណៈប្រតិភូបានផ្តល់អនុសាសន៍ថា មួយចំនួនធំនៃសារពើពន្ធលើកស្ទួយបន្ថែម គួរតែធ្វើឡើងតាមរយៈការបង្កើនចំណាយ ហើយការចំណាយច្រើននេះអាចទ្រទ្រង់ប្រកបដោយប្រសិទ្ធិភាពដល់កំណើនសេដ្ឋកិច្ច ។ ការចំណាយផ្តោតសំខាន់ទៅលើប្រព័ន្ធសង្គមកិច្ច ជួយដល់ជនក្រីក្រសំណាញ់សុវត្ថិភាព និងគំរោងហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ដែលជួយពង្រឹងភាពប្រកួតប្រជែង ។ គណៈប្រតិភូបានសំណូមពរអោយរាជរដ្ឋាភិបាលជៀសវៀងការស្រុតចុះក្នុងការគ្រប់គ្រងចំណូលពន្ធដារ ដែលជាហានិភ័យនៃការបាត់បង់ប្រភពចំណូលដែលកំពុងតែតូចស្រាប់នេះ ។

គណៈប្រតិភូ និង រាជរដ្ឋាភិបាលក៏បានឯកភាពគ្នាថា នៅមានលទ្ធភាពសំរាប់បន្ធូរបន្ថយនយោបាយរូបិយវត្ថុមួយក្នុងឆ្នាំ២០០៩ ដោយសារតែអតិផរណាបានធ្លាក់ចុះ ប៉ុន្តែលក្ខខណ្ឌសាច់ប្រាក់ងាយស្រួលសង្ឃឹមថានៅតែមានភាពរិតត្បិតក្នុងឆ្នាំនេះដោយសារលំហូរចូលពីខាងក្រៅបន្ថយល្បឿន ។ ធនាគារជាតិនៃកម្ពុជាបានចាត់វិធានការយ៉ាងក្រាស់ក្រែលដើម្បីឆ្លើយតបទៅនឹងសំពាធមកលើប្រព័ន្ធធនាគារ ដោយលក្ខណៈរិតត្បិតជាងនៃសាច់ប្រាក់ងាយស្រួល និងការធ្លាក់ចុះនៃសេដ្ឋកិច្ច ។ ជាពិសេសគណៈប្រតិភូបានស្វាគមន៍ការបង្កើតឧបការណ៍ដកសាច់ប្រាក់លើសឥណទានកំណត់ (Overdraft facility) ដើម្បីគ្រប់គ្រងហានិភ័យសាច់ប្រាក់រយៈពេលខ្លី និងការបង្កើតបទបញ្ញត្តិថ្មីដើម្បីពង្រឹងប្រព័ន្ធវត្ថី

ករណ៍ (classification system) សំរាប់ឥណទានដែលមិនដំណើរការ និងធ្វើបសិដ្ឋកម្ម នៃប្រព័ន្ធទុនបំរុងកាតព្វកិច្ច (reserve requirement system) ។

គណៈប្រតិភូបានស្វាគមន៍កិច្ចប្រឹងប្រែងរបស់ធនាគារជាតិក្នុងការពង្រឹងការត្រួតពិនិត្យធនាគារហើយពេលជាមួយគ្នានោះកែលំអររបបនិយតភាព ។ គណៈប្រតិភូបានឯកភាពថា ការរឹតបន្តឹងយ៉ាងខ្លាំងនៃបទបញ្ញត្តិប្រុងប្រយ័ត្ន នឹងជួយធានាសុវត្ថិភាពនៃប្រព័ន្ធធនាគារនៅប្រទេសកម្ពុជា ។